**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៧១៤៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី...១៣...ខែ...មីនា...ឆ្នាំ ២០១៧

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ៖** របាយការណ៍អំពីស្ថានភាពនៃការបំពេញបែបបទនាំចេញអង្ករប្រចាំខែកុម្ភៈដើមឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសគោរពជម្រាបជូន **សម្តេចអគ្គមហាសេនា-បតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា នៅរយៈពេល២ខែដើមឆ្នាំ២០១៧នេះ ស្ថានភាពនៃការនាំចេញអង្ករទៅក្រៅប្រទេសដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទទួលបានដោយផ្អែកលើប្រព័ន្ធទិន្នន័យគ្រឹះភូតគាមអនាម័យជាតិ National Phytosanitary Database (NPD/GDA from 07:00/01.01.2017 to 17:00/28.02.2017) ដែលជាតួលេខនៃការនាំចេញតាមរយៈការរៀបចំរវេចខ្ចប់គ្រប់ចំនួនរួចជាស្រេច និងបានឆ្លងកាត់ការត្រួតពិនិត្យភូតគាមអនាម័យដើម្បីនាំចេញមានដូចខាងក្រោម៖

១- *ស្ថានភាពនៃការនាំចេញអង្ករ៖*

- បរិមាណអង្ករនាំចេញមានចំនួន ៦០ ៧៣១ តោន មានការកើនឡើងចំនួន ៨ ៨១៩ តោន (+១៧%) លើសបរិមាណនាំចេញខែកុម្ភៈដើមឆ្នាំ២០១៦ (ដែលមាន ៥១ ៩១២ តោន)។ បរិមាណអង្ករដែលនាំចេញក្នុងរយៈពេល២ខែដើមឆ្នាំនេះ មានដល់ ១០៩ ៥៥១ តោន ដែលមានកំណើន ១៣ ៦០៦ តោន (+១៤,២%) លើសបរិមាណនាំចេញ២ខែដើមឆ្នាំមុន (សូមបង្ហាញជូនក្នុងតារាងទី១ នៃឧបសម្ព័ន្ធ១)

- អង្ករក្រអូបគ្រប់ប្រភេទមានបរិមាណនាំចេញដល់ ៦២ ៧៦៤ តោន ស្មើនឹង៥៧,២៩% ដែលមានបរិមាណ ច្រើនជាងបរិមាណអង្ករ ស គ្រប់ប្រភេទមានចំនួន ៣៧ ៨៦៧ តោន ស្មើនឹង ៣៤,៥៧% និង អង្ករចំហុយ ៨ ៩២០ តោន ស្មើនឹង ៨,១៤%។ ក្នុងចំណោមអង្ករក្រអូបនោះអង្ករក្រអូបចម្រុះមានបរិមាណនាំចេញ ៣៥ ៦៧៤ តោនស្មើនឹង ៣២,៥៦% អង្ករផ្ការំដួល/ផ្កាម្លិះមាន ២៤ ៣២៧ តោន ស្មើនឹង២២,២១%(សូមបង្ហាញជូនក្នុងតារាងទី២នៃឧបសម្ព័ន្ធ)

- ក្នុងខែកុម្ភៈដើមឆ្នាំ២០១៧ អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤៦ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (៤៦ ៣៨៧តោន) ប្រទេសបារាំងលំដាប់ទី២ (១៥ ៣១៨តោន) ប្រទេសប៉ូឡូញលំដាប់ទី៣ (៩ ១៣៦តោន) ប្រទេសអង់គ្លេសលំដាប់ទី៤ (៦ ៣៨៦តោន) ប្រទេសណេដឺឡែនលំដាប់ទី៥ (៥ ១៧៩តោន) ប្រទេសប៊ែលហ្ស៊ិកលំដាប់ទី៦ (៣ ១០៦តោន) ប្រទេសឆែកលំដាប់ទី៧ (៣ ០៥៧តោន) ប្រទេស អ៊ីតាលីលំដាប់ទី៨ (២ ៨៤៤តោន) ប្រទេសអាល្លឺម៉ង់លំដាប់ទី៩ (២ ២៧៦តោន) និងប្រទេសអេស្ប៉ាញ ឈរលំដាប់ទី១០ (១ ៥៦៤ តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហភាពអឺរ៉ុប២៤ប្រទេសមានបរិមាណ សរុប ៥៥ ៧២៦ តោន(៥១%) ទិសដៅអាស៊ាន៣ប្រទេសមានបរិមាណសរុប២ ២៨២តោន (២%) និងទិសដៅដទៃទៀត១៩ប្រទេសមានបរិមាណសរុប ៥១ ៥៤៣ តោន (៤៧%) (សូមបង្ហាញជូនក្នុងតារាងទី៣ នៃឧបសម្ព័ន្ធ)

- ការនាំចេញអង្ករមាន ៥៤ ក្រុមហ៊ុន ដែលបរិមាណអង្ករនាំចេញត្រូវបាននាំមុខគេដោយ៖ (ទី១).ក្រុមហ៊ុនBaitang Kampuchea មានចំនួន ១៤ ១៧៣ តោន (ទី២).ក្រុមហ៊ុន Cristal Rice មានចំនួន ៩ ៩០៩ តោន

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

(ទី៣).ក្រុមហ៊ុន Khmer Food Group មានចំនួន ៩ ៤២២ តោន (ទី៤).ក្រុមហ៊ុន Apsara Rice មានចំនួន ៧ ៤៥៧ តោន (ទី៥).ក្រុមហ៊ុន City Rice Import Export មានចំនួន ៦ ៩៩៦ តោន (ទី៦). ក្រុមហ៊ុន Amru Rice មានចំនួន ៦ ៦៦២ តោន(ទី៧). ក្រុមហ៊ុន Golden Riceចំនួន ៦ ៦៤៧ តោន (ទី៨).ក្រុមហ៊ុន Green Trade Company មានចំនួន ៥ ៧០០ តោន (ទី៩).ក្រុមហ៊ុន Nikoline Investment មានចំនួន ៥ ៤៣៤ តោន និង(ទី១០). ក្រុមហ៊ុន KOL VEASNA investment មានចំនួន ៥ ១២៥ តោន (សូមបង្ហាញជូនក្នុងតារាងទី៤ នៃឧបសម្ព័ន្ធ)។

២-សន្និដ្ឋានៈ

បរិមាណអង្ករនាំចេញសរុបក្នុងរយៈពេល២ខែដើមឆ្នាំ២០១៧ មានចំនួន ១០៩ ៥៥១តោន ដែលបរិមាណនេះមានកំណើនប្រមាណ+១៤,២% ធៀបនឹងបរិមាណនាំចេញក្នុងរយៈពេល២ខែដើមឆ្នាំ២០១៦។ កំណើនក្នុងខែមករាឆ្នាំនេះធៀបនឹងខែមករាឆ្នាំមុន មាន១០,៩% និងកំណើនក្នុងខែកុម្ភៈឆ្នាំនេះធៀបនឹងខែកុម្ភៈឆ្នាំមុន មាន ១៧% ជាសញ្ញាល្អ (ធៀបនឹងខែកុម្ភៈដូចគ្នាកាលពីឆ្នាំកន្លងមក) ដើម្បីសម្រេចនូវគោលដៅរំពឹងទុករបស់រាជរដ្ឋាភិបាលក្នុងការនាំចេញអង្ករឱ្យទទួលបានជោគជ័យ។

លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ ដែលជាសេនាធិការ របស់ក្រុមការងារទី៩ នឹងខិតខំបន្តពង្រីកវិសាលភាពដើម្បីបំពេញតួនាទីក្នុងការបង្កើនការយល់ដឹងដល់អ្នកពាក់ព័ន្ធ (សមត្ថកិច្ចដែលពាក់ព័ន្ធនឹងបែបបទនាំចេញអង្ករ ក្រុមហ៊ុននាំចេញអង្ករ រោងម៉ាស៊ីនកិនស្រូវ និងកែច្នៃអង្ករ ក្រុមហ៊ុនដឹកជញ្ជូន ។ល។ ដែលកំពុងមានសកម្មភាពពាក់ព័ន្ធនឹងការនាំចេញអង្ករ) ក្នុងការរៀបចំថែទាំស្រូវ អង្ករមុនការនាំចេញ និងបំពេញបែបបទដោយអនុលោមតាមលក្ខខ័ណ្ឌតម្រូវរបស់ប្រទេសនាំចូល និងរាល់កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយប្រទេសនាំចូលឲ្យបានសមស្របតាមស្តង់ដារភូតគាមអនាម័យទាំងបរិមាណ គុណភាព និងនីតិវិធីជាធរមាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**ចម្លងជូនៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានកសិកម្ម
- នាយកដ្ឋានផែនការនិងស្ថិតិ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

**វេង សាខុន**

# ឧបសម្ព័ន្ធៈ របាយការណ៍អំពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាប្រចាំខែ កុម្ភៈ ឆ្នាំ២០១៧

**(ANNEX: THE REPORT ON CAMBODIAN RICE EXPORT STATUS IN FEBRUARY , 2017)**

(Base on NPD/GDA from 07:00/01.01.2017 to 17:00/28.02.2017 and all number are English punctuation)

## តារាងទី១.បរិមាណអង្ករកម្ពុជាដែលបាននាំចេញប្រចាំខែ ក្នុងឆ្នាំ ២០១៣ - ២០១៧, គិតជាតោន

(Table1. Quantity of Cambodian Rice have been Exported by months of 2013-2017, in tones)

| | Month/ Year | 2013 | 2014 | 2015 | 2016 | 2017 | VARIATION |
|---|---|---|---|---|---|---|---|
| 1 | មករា (January) | 25,726 | 21,536 | 35,921 | 44,033 | 48,820 | +10.90% |
| 2 | កុម្ភៈ (February) | 24,089 | 27,037 | 37,676 | 51,912 | 60,731 | +17.00% |
| Sub-Total for 2 months | | 49,815 | 48,573 | 73,597 | 95,945 | 109,551 | +14.20% |
| 3 | មីនា (March) | 45,413 | 35,757 | 75,867 | 66,275 | | |
| 4 | មេសា (April) | 23,276 | 35,961 | 51,719 | 39,550 | | |
| 5 | ឧសភា ( May) | 28,350 | 27,971 | 41,842 | 32,558 | | |
| 6 | មិថុនា (June) | 29,105 | 29,666 | 40,800 | 33,862 | | |
| 7 | កក្កដា (July) | 31,411 | 26,060 | 28,492 | 24,087 | | |
| 8 | សីហា (August) | 29,358 | 29,871 | 29,819 | 27,799 | | |
| 9 | កញ្ញា (September) | 29,395 | 35,511 | 26,969 | 41,429 | | |
| 10 | តុលា (October) | 28,031 | 35,418 | 39,064 | 60,016 | | |
| 11 | វិច្ឆិកា (November) | 37,855 | 31,137 | 48,748 | 58,168 | | |
| 12 | ធ្នូ (December) | 46,847 | 51,136 | 81,479 | 62,455 | | |
| GRAND TOTAL | | 378,856 | 387,061 | 538,396 | 542,144 | | |

## តារាងទី២.ប្រភេទអង្ករកម្ពុជាដែលបាននាំចេញក្នុង២ខែដើមឆ្នាំ ២០១៧, គិតជាតោន

(Table 2. Type of Cambodian Rice have been Exported in February 2017, in tones)

| | ប្រភេទអង្ករ TYPE OF RICE | មករា JAN | កុម្ភៈ FEB | មីនា MAR | មេសា APR | ឧសភា MAY | មិថុនា JUN | សរុប (TOTAL) MT | % |
|---|---|---|---|---|---|---|---|---|---|
| **I. អង្ករក្រអូប /JASMINE/ FRAGRANT RICE:** | | | | | | | | | |
| 1 | ចម្រុះ (F.SENKRAOB, NEANG SAUY....) | 13,907 | 21,767 | | | | | 35,674 | 32.56 |
| 2 | នាងម្លិស (F. NEANG MALIS) | 117 | 166 | | | | | 283 | 0.26 |
| 3 | សូមាលី .( F. SOMALY) | 96 | 167 | | | | | 263 | 0.24 |
| 4 | ផ្ការំដួល /ផ្កាម្លិស/ (J.PHKA RUMDUOL/ MALIS) | 13,242 | 11,085 | | | | | 24,327 | 22.21 |
| 5 | សរីរាង្គ (J.ORGANIC) | 1,019 | 1,174 | | | | | 2,193 | 2.00 |
| 6 | ភ្លឺ . (F. PEARL) | 24 | | | | | | 24 | 0.02 |
| | SUB-TOTAL | 28,405 | 34,359 | | | | | 62,764 | 57.29 |
| **II.អង្ករសគ្រាប់វែង /WHITE LONG GRAIN RICE:** | | | | | | | | | |
| 1 | ចម្រុះគ្រាប់វែង (LONG GRAIN) | 16,823 | 19,017 | | | | | 35,840 | 32.72 |
| 2 | ប្រណិតគ្រាប់វែង (PREMIUM LONG GRAIN) | 935 | 1,092 | | | | | 2,027 | 1.85 |
| | SUB-TOTAL | 17,758 | 20,109 | | | | | 37,867 | 34.57 |
| **III.អង្ករចំហុយគ្រាប់វែង/ LONG GRAIN PABOILLED:** | | | | | | | | | |
| 1 | ចំហុយគ្រាប់វែង (LONG GRAIN PABOILLED) | 2,657 | 6,263 | | | | | 8,920 | 8.14 |
| | SUB-TOTAL | 2,657 | 6,263 | | | | | 8,920 | 8.14 |
| GRAND TOTAL | | 48,820 | 60,731 | | | | | 109,551 | 100 |

## តារាងទី៣.ទិសដៅនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល២ខែដើមឆ្នាំ ២០១៧, គិតជាតោន

(Table 3. Export Destination of Cambodian Rice in 2 Month of 2017, in tones)

| | ប្រទេសទិសដៅ<br>COUNTRY DESTINATION | មករា<br>JAN | កុម្ភៈ<br>FEB | មីនា<br>MAR | មេសា<br>APR | ឧសភា<br>MAY | មិថុនា<br>JUN | សរុប (TOTAL)<br>MT |
|---|---|---|---|---|---|---|---|---|
| | **I.សមាជិកសហគមន៍អឺរ៉ុប /EUROPEAN UNION** | | | | | | | |
| 1 | FRANCE | 8,230 | 7,088 | | | | | 15,318 |
| 2 | POLAND | 4,760 | 4,376 | | | | | 9,136 |
| 3 | UNITED KINGDOM | 2,432 | 3,954 | | | | | 6,386 |
| 4 | NETHERLAND | 2,219 | 2,960 | | | | | 5,179 |
| 5 | BELGIUM | 1,277 | 1,829 | | | | | 3,106 |
| 6 | CZECH REPUBLIC | 1,034 | 2,023 | | | | | 3,057 |
| 7 | ITALY | 2,001 | 843 | | | | | 2,844 |
| 8 | GERMANY | 1,332 | 944 | | | | | 2,276 |
| 9 | SPAIN | 749 | 815 | | | | | 1,564 |
| 10 | LATIVIA | 1,000 | **525** | | | | | 1,525 |
| 11 | PORTUGAL | 749 | 336 | | | | | 1,085 |
| 12 | SWEEDEN | 613 | 337 | | | | | 950 |
| 13 | GREECE | 358 | 340 | | | | | 698 |
| 14 | DENMARK | 273 | 335 | | | | | 608 |
| 15 | LITHUANIA | - | 546 | | | | | 546 |
| 16 | CROATIA | - | 400 | | | | | 400 |
| 17 | AUSTRIA | 147 | 115 | | | | | 262 |
| 18 | HUNGARY | 89 | 125 | | | | | 214 |
| 19 | ROMANIA | - | 150 | | | | | 150 |
| 20 | SLOVENIA | 72 | 72 | | | | | 144 |
| 21 | ESTONIA | 25 | 100 | | | | | 125 |
| 22 | FINLAND | 63 | - | | | | | 63 |
| 23 | CYPRUS | 24 | 24 | | | | | 48 |
| 24 | IRELAND | 24 | 18 | | | | | 42 |
| | SUB-TOTAL | **27,471** | **28,255** | | | | | **55,726 = (51%)** |
| | **II. សមាជិកអាស៊ាន/ASEAN MEMBER STATE** | | | | | | | |
| 1 | MALAYSIA | 529 | 529 | | | | | 1,058 |
| 2 | BRUNEI | - | 924 | | | | | 924 |
| 3 | SINGAPORE | 138 | 162 | | | | | 300 |
| | SUB-TOTAL | 667 | **1,615** | | | | | **2,282=(2%)** |
| | **III.ទិសដៅផ្សេងទៀត /OTHERS DESTINATION** | | | | | | | |
| 1 | CHINA | 18,383 | 28,004 | | | | | **46,387** |
| 2 | GABON | - | 1,292 | | | | | 1,292 |
| 3 | HONG KONG | 1,006 | 88 | | | | | 1,094 |
| 4 | TURKEY | 500 | 506 | | | | | 1,006 |
| 5 | SENEGAL | - | 250 | | | | | 250 |
| 6 | RUSSIAN FED | 245 | - | | | | | 245 |
| 7 | MAYOTTE | 96 | 148 | | | | | 244 |
| 8 | IRAQ | - | 230 | | | | | 230 |
| 9 | AUSTRALIA | 142 | 38 | | | | | 180 |
| 10 | USA | 58 | 80 | | | | | 138 |
| 11 | CONGO | 120 | - | | | | | 120 |
| 12 | CANADA | 85 | - | | | | | 85 |
| 13 | NEWZEALAND | 23 | 47 | | | | | 70 |
| 14 | SAUDI ARABIA | - | 50 | | | | | 50 |
| 15 | KENYA | - | 50 | | | | | 50 |
| 16 | CAMAROON | - | 48 | | | | | 48 |
| 17 | REUNION | 24 | - | | | | | 24 |
| 18 | MOLDOVA | - | 24 | | | | | 24 |
| 19 | KOREA | - | 6 | | | | | 6 |
| | SUB-TOTAL | 20,682 | **30,861** | | | | | **51,543= (47%)** |
| | GRAND TOTAL | 48,820 | 60,731 | | | | | 109,551= (100%) |

## តារាងទី៤.ក្រុមហ៊ុននិងបរិមាណដែលបានធ្វើការនាំចេញអង្ករកម្ពុជា២ខែដើមឆ្នាំ ២០១៧,គិតជាតោន

(Table 4.Cambodian Rice Exporters and export quantity 2 Months of 2017, in tones)

| | ក្រុមហ៊ុននាំចេញអង្ករ<br>RICE EXPORTERS | មករា<br>JAN | កុម្ភៈ<br>FRA | មីនា<br>MAR | សរុប (TOTAL)<br>MT | <br>% |
|---|---|---|---|---|---|---|
| 1 | BAITANG (KAMPUCHEA) PLC. | 4,903 | 9,270 | | 14,173 | 12.94 |
| 2 | CRISTAL RICE (Kampuchea) co., ltd. | 3,961 | 5,948 | | 9,909 | 9.05 |
| 3 | KHMER FOODS GROUP CO.,LTD. | 3,573 | 5,849 | | 9,422 | 8.60 |
| 4 | APSARA RICE (CAMBODIA) CO., LTD | 2,110 | 5,347 | | 7,457 | 6.81 |
| 5 | CITY RICE IMPORT EXPORT CO., LTD. | 3,961 | 3,035 | | 6,996 | 6.39 |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | AMRU RICE (CAMBODIA) CO.,LTD | 3,153 | 3,509 | | 6,662 | 6.08 |
| 7 | GOLDEN RICE (CAMBODIA) CO.,LTD. | 3,167 | 3,480 | | 6,647 | 6.07 |
| 8 | GREEN TRADE COMPANY | 2,700 | 3,000 | | 5,700 | 5.20 |
| 9 | NIKOLINE INVESTMENT CO., LTD. | 3,919 | 1,515 | | 5,434 | 4.96 |
| 10 | KOL VEASNA investment co., ltd. | 2,875 | 2,250 | | 5,125 | 4.68 |
| 11 | INTERNATIONAL RICE TRADING (CAMBODIA) CO.,LTD. | 2,200 | 1,874 | | 4,074 | 3.72 |
| 12 | SIGNATURES OF ASIA CO.,LTD | 1,965 | 1,915 | | 3,880 | 3.54 |
| 13 | INDOCHINA RICE MILL LIMITED | 1,101 | 2,164 | | 3,265 | 2.98 |
| 14 | W.K.R TRADING CO.,LTD | 1,616 | 1,325 | | 2,941 | 2.68 |
| 15 | GOLDEN DAUN KEO RICE MILL CO., LTD | 546 | 2,084 | | 2,630 | 2.40 |
| 16 | SSCORP(CAMBODIA) CO.,LTD | 772 | 808 | | 1,580 | 1.44 |
| 17 | LOR EAK HENG SEK MEAS RICE CO., LTD | 799 | 613 | | 1,412 | 1.29 |
| 18 | T.O.T (TRUST OUR TRADE) CO., LTD. | 942 | 368 | | 1,310 | 1.20 |
| 19 | PRIMALIS CORPORATION LTD. | - | 1,293 | | 1,293 | 1.18 |
| 20 | Mekong Oryza trading co., ltd. | 75 | 1,094 | | 1,169 | 1.07 |
| 21 | BATTAMBANG RICE INVESTMENT CO., LTD | 452 | 685 | | 1,137 | 1.04 |
| 22 | CK RICE TRADING CO., LTD. | 549 | 260 | | 809 | 0.74 |
| 23 | SOMA TRADING COMPANY LIMITED | - | 625 | | 625 | 0.57 |
| 24 | HERBA (Cambodia) Co.,ltd | 295 | 300 | | 595 | 0.54 |
| 25 | AMRU and Hanwha international co., ltd | 92 | 479 | | 571 | 0.52 |
| 26 | FED RICE BATTAMBANG LTD | 159 | 350 | | 509 | 0.46 |
| 27 | COMMODITY IN FOCUS CO., LTD. | 350 | 150 | | 500 | 0.46 |
| 28 | GLOBAL ECOLOGICAL RICE (CAMBODIA) CO., LTD | 490 | - | | 490 | 0.45 |
| 29 | LIM KHEANG HOUT IMPORT EXPORT CO., LTD. | 311 | 167 | | 478 | 0.44 |
| 30 | WHITE GOLD IMPORT EXPORT CO,. LTD. | 46 | 302 | | 348 | 0.32 |
| 31 | Golden Star Rice Mill and Import Export Co., Ltd | 315 | - | | 315 | 0.29 |
| 32 | OVERSEAS FOODS IMPORT EXPORT CO.,LTD | 100 | 122 | | 222 | 0.20 |
| 33 | OU TONG DEVELOPMENT (CAMBODIA) CO., LTD | 79 | 109 | | 188 | 0.17 |
| 34 | HUNG HIEP (CAMBODIA) CO., LTD | 170 | - | | 170 | 0.16 |
| 35 | PHOU POY DEVELOPMENT IMPORT EXPORT CO., LTD | 98 | 68 | | 166 | 0.15 |
| 36 | CAM-GRAIN DEVELOPMENT CO., LTD. | 165 | - | | 165 | 0.15 |
| 37 | Cambodia diamond seafood and agriculture Co.,ltd | 140 | - | | 140 | 0.13 |
| 38 | KAMPONG THOM RICE MILL LIMITED. | 100 | 25 | | 125 | 0.11 |
| 39 | CAMBODIAN li shine international trade co.,ltd | 100 | - | | 100 | 0.09 |
| 40 | VONG BUNHENG IMPORT EXPORT CO., LTD | 96 | - | | 96 | 0.09 |
| 41 | Cambodian organic farm enterprise (c.o.f.e) co., ltd | 24 | 60 | | 84 | 0.08 |
| 42 | ANGKOR KASEKAM ROONGROEUNG CO.,LTD. | 24 | 53 | | 77 | 0.07 |
| 43 | DOMNAK TEUK GROUP CO.,LTD | 73 | - | | 73 | 0.07 |
| 44 | BAYON JASMINE RICE CO.,LTD | 72 | - | | 72 | 0.07 |
| 45 | LK INTERNATIONAL GROUP PLC. | - | 67 | | 67 | 0.06 |
| 46 | Jasmine Rice Mill Factory Co., Ltd. | 66 | - | | 66 | 0.06 |
| 47 | v-lotte trading co., ltd | - | 50 | | 50 | 0.05 |
| 48 | MUFAVOR INTERNATIONAL (CAMBODIA) INC. | - | 43 | | 43 | 0.04 |
| 49 | HUA FENG YUAN RICE VERMICELLI (Cambodia) | 36 | - | | 36 | 0.03 |
| 50 | MILIN RICE (CAMBODIA) IMPORT EXPORT CO.,LTD | 30 | - | | 30 | 0.03 |
| 51 | RICEPADDY FIELDS (CAMBODIA) CO., LTD. | - | 25 | | 25 | 0.02 |
| 52 | LBN ANGKAR (KAMPUCHEA) CO., LTD | 25 | - | | 25 | 0.02 |
| 53 | AROMARICE IMPORT EXPORT CO., LTD | - | 25 | | 25 | 0.02 |
| 54 | BAYON CEREAL CO., LTD | - | 25 | | 25 | 0.02 |
| GRAND TOTAL | | 48,820 | 60,731 | | 109,551 | 100 |

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិនា ឆ្នាំ២០១៧
អ្នករៀបចំសរុបទិន្នន័យ

ឌិន នរិន្ទ

បានឃើញ និង ឯកភាព
ប្រធានលេខាធិការដ្ឋាន
ច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករ

ឯកឧត្តមបណ្ឌិត ហ៊ាន វណ្ណហាន